# អេស៊ីលីដា ត្រេននីង សេនធ័រ
# ACLEDA Training Center Ltd.

**ការិយាល័យកណ្តាល**

លេខ : អត្រស ១៨៧៩ /១៤

**អគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ**

**គោរពជូន**

**តំណាងសមាជិកសមាជិកា ក្រុមគ្រូហ្វឹកហ្វឺននៃនាយកដ្ឋាន ទីផ្សារ អភិវឌ្ឍន៍ផលិតផលការិយាល័យនីតិកម្ម ការិយាល័យលេខាធិការក្រុមហ៊ុន ការិយាល័យធនធានមនុស្ស ការិយាល័យពិធីការ និងសុខុមាលភាព ការិយាល័យរដ្ឋបាល និងក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី**

**កម្មវត្ថុ :** **ស្តីពីវគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មីសម្រាប់ មុខតំណែង « ជំនួយការបម្រើអតិថិជន »**

**យោង :**
- សេចក្តីសម្រេចលេខ : អត្រស ០៩៧/១៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវគោលការណ៍ប្រតិបត្តិ ហ្វឹកហ្វឺន និងអភិវឌ្ឍន៍ធនធានមនុស្ស ។
- អនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការ និងគាំទ្រ លើសេវាហ្វឹកហ្វឺនផ្ទៃក្នុងកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី រវាង ធនាគារ អេស៊ីលីដា ភីអិលស៊ី និង អេស៊ីលីដា ត្រេននីង សេនធ័រ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣ និងការធ្វើវិសោធនកម្ម ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ ។
- សេចក្តីសម្រេចលេខ : អត្រស ២៨៤៧/១៣ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីហ្វឹកហ្វឺនកម្មករនិយោជិតថ្មី របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- លិខិតលេខ : កធម ២៣៥៤/១៤ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ស្តីពីតម្រូវការរៀបចំបើកវគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ អេស៊ីលីដា ត្រេននីង សេនធ័រ នឹងមានរៀបចំបើកវគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី ដែលនឹងប្រព្រឹត្តទៅចាប់ពី**ថ្ងៃទី១៩** ដល់**ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤** នៅ**អេស៊ីលីដា ត្រេននីង សេនធ័រ** ( **ជាន់ទី២ បន្ទប់ប្រាសាទបាយ័ន** ) ដែលមានទីតាំងស្ថិតនៅ **អគារលេខ៥០ ផ្លូវលេខ៥១៦ កែង៣៣៥ ភូមិ៦ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ**។

អេស៊ីលីដា ត្រេននីង សេនធ័រ សូមអញ្ជើញតំណាងសមាជិក-សមាជិកាក្រុមគ្រូហ្វឹកហ្វឺន នៃនាយកដ្ឋាន ទីផ្សារ អភិវឌ្ឍន៍ផលិតផល ការិយាល័យនីតិកម្ម ការិយាល័យលេខាធិការក្រុមហ៊ុន ការិយាល័យធនធានមនុស្ស ការិយាល័យពិធីការ និងសុខុមាលភាព ការិយាល័យរដ្ឋបាល និងក្រុមហ៊ុនអេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ដើម្បីចូលរួមដឹកនាំមេរៀនតាមកម្មវិធីដូចបានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុនេះ សូមតំណាង ក្រុមគ្រូហ្វឹកហ្វឺននៃនាយកដ្ឋាន ការិយាល័យ និងក្រុមហ៊ុនខាងលើ មេត្តាចាត់ចែងឲ្យសមាជិក-សមាជិកាក្រុមគ្រូហ្វឹកហ្វឺន រៀបចំឯកសារមេរៀនផ្ញើមកផ្នែកហ្វឹកហ្វឺនខាងក្នុង ដើម្បីរៀបចំថតចម្លង ឯកសារឲ្យបានទាន់ពេល ។

ដោយក្តីគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤

**ជ, អគ្គនាយក**

**នាយិកាការិយាល័យសិក្សា និងកិច្ចការនិស្សិត**

This is an electronic letter sent by Sovanne Tourt

**ផ្ញើនភ្ជាប់មកជាមួយ** :

- កាលវិភាគហ្វឹកហ្វឺន

**ចម្លងជូន** :

- ទីប្រឹក្សាអេស៊ីលីដា ត្រេននីង សេនធ័រ
- នាយិកាប្រតិបត្តិទីផ្សារ
- នាយកប្រតិបត្តិអភិវឌ្ឍន៍ផលិតផល
- នាយិកាការិយាល័យទំនាក់ទំនងអតិថិជន

« **ដើម្បីជូនជ្រាបជាព័ត៌មាន** »

- ឯកសារ - កាលប្បវត្តិ